# មេរោគរ៉ូតាវីរ៉ុស

ព័ត៌មានអំពីការចាក់ថ្នាំបង្ការរោគ

## មេរោគរ៉ូតាវីរ៉ុស

មេរោគរ៉ូតាវីរ៉ុស (rotavirus) បណ្តាលឱ្យកើតទម្រង់ធ្ងន់ធ្ងរនៃជំងឺរលាកក្រពះពោះវៀន។ មនុស្សមួយចំនួនមិនបង្ហាញឱ្យឃើញរោគសញ្ញាទេ ប៉ុន្តែកុមារ វ័យក្មេងទំនងជាកើតមានរោគសញ្ញាធ្ងន់ធ្ងរចាប់ពីជំងឺរាគរូសស្រាល រហូតដល់ជំងឺរាគរូសខ្សោះជាតិទឹកដែលគំរាមកំហែងដល់ជីវិត ដែលតម្រូវឱ្យដេក សម្រាកព្យាបាលក្នុងមន្ទីរពេទ្យ និងអាចបណ្តាលឱ្យស្លាប់បាន។

កម្មវិធីជាតិស្តីពីការចាក់ថ្នាំបង្ការរោគរ៉ូតាវីរ៉ុសបានចាប់ផ្តើមក្នុងឆ្នាំ២០០៧ ហើយគេប៉ាន់ប្រមាណថាចំនួនអ្នកជំងឺចូលដេកព្យាបាលក្នុងមន្ទីរពេទ្យបាន ថយចុះជាង៧,០០០នាក់ ជារៀងរាល់ឆ្នាំ។ អស់អ្នកដែលបានចូលដេកព្យាបាលក្នុងមន្ទីរពេទ្យ ជាទូទៅមិនសូវរងផលប៉ះពាល់ខ្លាំងទេ។

អ្នកអាចកាត់បន្ថយហានិភ័យនៃការឆ្លងមេរោគរ៉ូតាវីរ៉ុសសម្រាប់កូនរបស់អ្នក តាមរយៈការចាក់ថ្នាំបង្ការរោគ។ កុមារទាំងអស់គួរតែបានទទួលថ្នាំចាក់បង្ការ រោគ។ ប្រសិនបើពួកគេមិនបានចាក់ថ្នាំបង្ការរោគទេ ពួកគេអាចឆ្លងមេរោគរ៉ូតាវីរ៉ុស បើចំណីអាហារ ទឹក ឬដៃរបស់ពួកគេបានប្រឡាក់ជាមួយនឹងលាមក (អាចម៍) របស់អ្នកមានមេរោគឆ្លងនេះ។

ផលប៉ះពាល់ធ្ងន់ធ្ងរ ឬប្រតិកម្មទាស់ទៅនឹងថ្នាំចាក់បង្ការរោគគឺកម្រកើតមានណាស់។ ប្រសិនបើអ្នកព្រួយបារម្ភអំពីប្រតិកម្មរបស់កូនអ្នកទៅនឹងថ្នាំចាក់ បង្ការរោគណាមួយ សូមពិគ្រោះជាមួយវេជ្ជបណ្ឌិតរបស់អ្នកភ្លាម។

## ការចាក់ថ្នាំបង្ការរោគរ៉ូតាវីរ៉ុស

មានផ្តល់ជូនការការពារប្រឆាំងនឹងមេរោគរ៉ូតាវីរ៉ុសដោយឥតគិតថ្លៃ នៅក្រោមគម្រោងកម្មវិធីជាតិស្តីពីការចាក់ថ្នាំបង្ការរោគ។ នៅក្នុងរដ្ឋវិចតូរីយ៉ា ការចាក់ ថ្នាំបង្ការរោគប្រឆាំងនឹងមេរោគរ៉ូតាវីរ៉ុស មានផ្តល់ជូនដោយឥតគិតថ្លៃសម្រាប់ទារក ហើយត្រូវបានផ្តល់ជាថ្នាំលេបក្នុងកម្រិតពីរដូស សម្រាប់ទារកអាយុ ពីរខែ និងបួនខែ។ កម្រិតដូសដំបូងត្រូវផ្តល់ឱ្យត្រឹមពេលដែលទារកមានអាយុ១៤សប្តាហ៍ និងប្រាំមួយថ្ងៃ ហើយកម្រិតដូសទីពីរត្រូវផ្តល់ឱ្យត្រឹមអាយុ ២៤សប្តាហ៍ និងប្រាំមួយថ្ងៃ។

ថ្នាំចាក់បង្ការរោគនេះ មិនការពារប្រឆាំងនឹងប្រភេទដទៃទៀតនៃជំងឺរាគរូសទេ ប៉ុន្តែវាជួយកាត់បន្ថយហានិភ័យនៃជំងឺរាគរូសដែលគំរាមកំហែងដល់ជីវិត បណ្តាលឡើងដោយមេរោគរ៉ូតាវីរ៉ុស។

## បញ្ជីត្រួតពិនិត្យមុនការចាក់ថ្នាំបង្ការរោគ

មុនពេលទទួលថ្នាំចាក់បង្ការរោគ សូមប្រាប់វេជ្ជបណ្ឌិត ឬគិលានុបដ្ឋាករបស់អ្នក ប្រសិនបើកូនរបស់អ្នក៖

- មានអាយុច្រើនជាងអាយុដូចបានណែនាំសម្រាប់កម្រិតដូសណាមួយ
- មិនស្រួលខ្លួន (ក្តៅខ្លួនដោយមានសីតុណ្ហភាពជាង 38.5°C)
- មានប្រតិកម្មធ្ងន់ធ្ងរទៅនឹងថ្នាំចាក់បង្ការរោគណាមួយ
- មានប្រតិកម្មទាស់ធ្ងន់ធ្ងរទៅនឹងអ្វីមួយ
- មានជំងឺពោះវៀនលូនចូលគ្នា ឬលក្ខណៈខុសប្រក្រតីពីកំណើត ដែលអាចបណ្តាលឱ្យមានជំងឺពោះវៀនលូនចូលគ្នា
- កំពុងប្រើថ្នាំស្តេរ៉ូអ៊ីត (steroid)

Victoria State Government
Health and Human Services

- បានទទួលការចាក់បញ្ចូលឈាម ឬផលិតផលឈាម
- បានធ្វើឱ្យប្រព័ន្ធការពាររាងកាយពីជំងឺចុះខ្សោយ ដោយសារតែកង្វះខាតនៃប្រព័ន្ធការពាររាងកាយពីជំងឺ ស្ថានភាព ឬអាការៈជំងឺឈាមមិនប្រក្រតី ជំងឺមហារីក មេរោគ HIV ឬថ្នាំពេទ្យមួយចំនួន
- ប្រសិនបើនរណាម្នាក់នៅក្នុងគ្រួសាររបស់អ្នក មានប្រព័ន្ធការពាររាងកាយពីជំងឺចុះខ្សោយ។

## ផលប៉ះពាល់នៃថ្នាំចាក់បង្ការរោគរ៉ូតាវីរ៉ុស

ថ្នាំចាក់បង្ការរោគប្រឆាំងនឹងមេរោគរ៉ូតាវីរ៉ុសមានប្រសិទ្ធភាព ហើយមានសុវត្ថិភាព ទោះបីជារាល់ថ្នាំទាំងអស់អាចមានផលប៉ះពាល់ដែលមិនចង់បាន។

ផលប៉ះពាល់ទាំងនេះ អាចរួមមាន៖

- លាមករបស់ទារកមួយចំនួនអាចមានផ្ទុកមេរោគរ៉ូតាវីរ៉ុស បន្ទាប់ពីការថ្នាំចាក់បង្ការរោគ - គួរតែលាងដៃឱ្យបានស្អាតជានិច្ច បន្ទាប់ពីផ្លាស់ប្តូរខោទឹកនោម ហើយអ្នកដែលមានប្រព័ន្ធការពាររាងកាយពីជំងឺចុះខ្សោយ គួរជៀសវាងការប៉ះពាល់ខោទឹកនោមកខ្វក់ក្នុងអំឡុងពេលនេះ។

## ផលប៉ះពាល់កម្រនៃការចាក់ថ្នាំបង្ការរោគ

មានហានិភ័យតិចតួចណាស់នៃប្រតិកម្មទាស់ធ្ងន់ធ្ងរ (anaphylaxis) ទៅនឹងថ្នាំចាក់បង្ការរោគណាមួយ។ នេះគឺជាមូលហេតុដែលអ្នកត្រូវបានណែនាំឱ្យស្នាក់នៅមន្ទីរចាក់ថ្នាំ ឬបន្ទប់វះកាត់ផ្នែកវេជ្ជសាស្ត្រសម្រាប់រយៈពេលយ៉ាងហោចណាស់១៥នាទី បន្ទាប់ពីបានចាក់ថ្នាំបង្ការរោគ ក្នុងករណីត្រូវការការព្យាបាលបន្ថែមទៀត។

ជំងឺពោះវៀនលូនចូលគ្នា (ការស្ទះបណ្តាលមកពីផ្នែកមួយនៃពោះវៀនធ្លាក់ចូលទៅក្នុងផ្នែកបន្ទាប់នៃពោះវៀន ដូចបំណែកនៃកែវយឺត) ដែលអាចកើតមានឡើង (ក្នុងឱកាសកម្រ) ចំពោះទារកក្នុងរយៈពេលបីសប្តាហ៍បន្ទាប់ពីបានទទួលកម្រិតដូសទីមួយ ឬកម្រិតទីពីរនៃថ្នាំចាក់បង្ការរោគរ៉ូតាវីរ៉ុស។ រោគសញ្ញាដែលទារកអាចមានជំងឺពោះវៀនលូនចូលគ្នា រួមមាន៖

- ការស្រែកយំជំទាល
- កើតមានទឹកមុខស្លេកស្លាំង
- ការទាញជើងឡើងទៅដល់ពោះ។

ការសិក្សានាពេលថ្មីៗនេះនៅក្នុងប្រទេសអូស្ត្រាលី និងនៅបរទេសបានបង្ហាញថា មានការកើនឡើងបន្តិចបន្តួចនៃហានិភ័យនៃការកើតជំងឺពោះវៀនលូនចូលគ្នាក្នុងចំណោមទារកទាំងឡាយ ក្នុងរយៈពេលបីសប្តាហ៍ដំបូងបន្ទាប់ពីទទួលបានកម្រិតដូសទីមួយ និងទីពីរនៃថ្នាំចាក់បង្ការរោគរ៉ូតាវីរ៉ុស។ ហានិភ័យគឺមានប្រហែលជាប្រាំមួយករណីបន្ថែមទៀតនៃការកើតជំងឺពោះវៀនលូនចូលគ្នា ក្នុងចំណោមរៀងរាល់ទារក១០០,០០០នាក់ដែលបានចាក់ថ្នាំបង្ការរោគ ឬទារក១៤នាក់បន្ថែមទៀតក្នុងមួយឆ្នាំ ដែលកើតជំងឺពោះវៀនលូនចូលគ្នានៅក្នុងប្រទេសអូស្ត្រាលី។

## កន្លែងទទួលបានជំនួយ

- វេជ្ជបណ្ឌិតរបស់អ្នក
- សេវាចាក់ថ្នាំបង្ការរោគនៅតាមសាលាក្រុងរបស់អ្នក
- បណ្តាញ Health Channel https://www.betterhealth.vic.gov.au/health/healthyliving/rotavirus-immunisation

ដើម្បីទទួលយកខិត្តប័ណ្ណនេះក្នុងទម្រង់ដែលអាចចូលយកបាន សូមទូរស័ព្ទលេខ 1300 882 008 ដោយប្រើប្រាស់ National Relay Service លេខ 13 36 77 ប្រសិនបើតម្រូវ ឬអ៊ីម៉េល immunisation@dhhs.vic.gov.au

អនុញ្ញាត និងបោះពុម្ពផ្សាយដោយរដ្ឋាភិបាលវិចតូរីយ៉ា 1 Treasury Place, Melbourne។

© រដ្ឋវិចតូរីយ៉ា Department of Health and Human Services ខែមិថុនា ឆ្នាំ២០១៧។